ក្រុមហ៊ុនមេធាវី តម្រាច្បាប់
LEGAL CODE LAW FIRM

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លេខ: ០១ តរច/សជណ/២២

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសសមាជិកក្រុមការងារស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់
# នៃក្រុមហ៊ុនមេធាវីតម្រាច្បាប់

**ក្រុមហ៊ុនមេធាវី តម្រាច្បាប់** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងនិស្សិតជំនាញនីតិសាស្ត្រទាំងអស់ឱ្យបានជ្រាបថា ក្រុមហ៊ុនមេធាវីតម្រាច្បាប់ បាននិងកំពុងដំណើរការស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់យ៉ាងសកម្ម លើគម្រោងនៃការផ្សព្វផ្សាយច្បាប់តាមរយៈកម្មវិធី "**បណ្ណាល័យតម្រាច្បាប់**" **(MobileApp)** និងគម្រោងថ្មីបន្ថែមទៀតជាអាទិ៍ កម្មវិធីបណ្តុះបណ្តាលជំនាញផ្នែកច្បាប់, ការផលិតនូវវីដេអូអប់រំ និងផ្សព្វផ្សាយច្បាប់, ការបង្កើតនូវកម្មវិធីប្រកួតប្រជែងចំណេះដឹងផ្នែកច្បាប់ និងសិក្ខាសាលាផ្សេងៗទៀតជាច្រើន ។ ហេតុនេះ ក្រុមហ៊ុនមេធាវីតម្រាច្បាប់ មានតម្រូវការចាំបាច់នៅក្នុងការជ្រើសរើសនូវសមាជិកចំនួន **១៥ នាក់** បន្ថែមទៀត សម្រាប់ការចូលរួមដោយស្ម័គ្រចិត្ត នៅក្នុងសកម្មភាពស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ របស់ក្រុមហ៊ុន ។ ដូច្នេះ តាមរយៈសេចក្តីជូនដំណឹងខាងលើនេះ បានផ្តល់ឱកាសដល់និស្សិតជំនាញនីតិសាស្ត្រ និងអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងចង់ចូលរួមបំពេញការងារដោយស្ម័គ្រចិត្ត ក្នុងវិស័យច្បាប់ ទទួលបាននូវចំណេះដឹង និងបទពិសោធន៍ ក្នុងក្របខណ្ឌការងារជាសមាជិកនៃក្រុមការងារស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ ស្របតាមលក្ខខណ្ឌនៃការជ្រើសរើសដូចខាងក្រោម៖

**១.លក្ខខណ្ឌនៃការជ្រើសរើស**

១.១ និស្សិតដែលកំពុងសិក្សាជំនាញនីតិសាស្ត្រ ចាប់ពីឆ្នាំទី២ ឡើងទៅ ឬសាធារណជនទូទៅដែលស្រឡាញ់ការចែករំលែកចំណេះដឹង និងមានជំនាញស្របតាមលក្ខខណ្ឌក្នុងចំណុចទី ១.៤ និង ១.៥ ខាងក្រោម ។

១.២ មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាស្រាវជ្រាវ រៀបចំ, ចងក្រង, តាក់តែង និងផ្សព្វផ្សាយច្បាប់ ។

១.៣ ចេះប្រើប្រាស់នូវកម្មវិធី Microsoft Word និង Microsoft Excel ។

១.៤ លើកទឹកចិត្តចំពោះបេក្ខជន ឬបេក្ខនារី ដែលមានសមត្ថភាពអាចប្រើប្រាស់នូវកម្មវិធី កាត់តវីដេអូ, រូបភាព, សំឡេង និងកម្មវិធីបច្ចេកវិទ្យាផ្សេងទៀត ។

១.៥ លើកទឹកចិត្តចំពោះបេក្ខជន ឬបេក្ខនារី ដែលមានជំនាញពិធីការ និងអាចធ្វើជាពិធីករ, ពិធីការនី ។

១.៦ មានលក្ខណៈសម្បត្តិល្អ និងឥរិយាបថចេះសម្របសម្រួលការងារជាក្រុម ។

១.៧ ឧស្សាហ៍ព្យាយាម និងមានទំនួលខុសត្រូវខ្ពស់ ចំពោះការងាររបស់ខ្លួន ។

១.៨ មានការប្តេជ្ញាខ្ពស់ និងមានភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទង ។



ផ្ទះលេខ ១៨១ ផ្លូវ ១៥០ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Address: #181, St.150, Sangkat Tuek L'ak Ti Pir, Khan Toul Kork, Phnom Penh.
Tel: (+855) 86 262 630 / 92 299 934
Email:info@legalcodecambodia.com

**២.ការងារដែលត្រូវបំពេញ**

២.១ ចូលរួមសកម្មភាពសិក្សាស្រាវជ្រាវ, រៀបចំ, ចងក្រង, តាក់តែង និងផ្សព្វផ្សាយច្បាប់ ។

២.២ ចូលរួមក្នុងសកម្មភាពផលិតនូវវីដេអូអប់រំ និងផ្សព្វផ្សាយច្បាប់ តាមរយៈការសម្ដែង ឬរៀបចំដឹកនាំសកម្មភាពសម្ដែង តាមភាពចាំបាច់នៃការប្រព្រឹត្តទៅផ្សេងៗទៀត ។

២.៣ ធ្វើបច្ចុប្បន្នភាពគតិយុត្តតាមរយៈការស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ ។

២.៤ ចូលរួមកិច្ចប្រជុំតាមការកំណត់របស់ប្រធានក្រុមហ៊ុន ។

២.៥ ការងារសិក្សាស្រាវជ្រាវផ្សេងៗទៀត តាមការកំណត់របស់ប្រធានក្រុមហ៊ុន ។

**៣.អត្ថប្រយោជន៍ដែលទទួលបាន**

៣.១ ទទួលបានវិញ្ញាបនបត្រ បញ្ជាក់អំពីសមាជិកភាពនៃក្រុមការងារស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ ដែលចេញដោយលោកប្រធានក្រុមហ៊ុនមេធាវី តម្រាច្បាប់ ។

៣.២ ទទួលបានចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យច្បាប់ តាមរយៈការចែករំលែក និងការបណ្ដុះបណ្ដាលរបស់មេធាវីប្រចាំក្រុមហ៊ុនមេធាវីតម្រាច្បាប់ និងសាស្ត្រាចារ្យដែលជាវាគ្មិនផ្សេងទៀត ។

៣.៣ ទទួលបានសិទ្ធិអាទិភាព ក្នុងការជ្រើសរើសជាបុគ្គលិកពេញសិទ្ធិនៃក្រុមហ៊ុនមេធាវីតម្រាច្បាប់ ។

៣.៤ ទទួលបានសិទ្ធិអាទិភាព ក្នុងការជ្រើសរើសឱ្យសិក្សាក្នុងវគ្គបណ្ដុះបណ្ដាល និងកម្មវិធីផ្សព្វផ្សាយច្បាប់ផ្សេងៗទៀត ដែលរៀបចំឡើងដោយក្រុមហ៊ុនមេធាវីតម្រាច្បាប់ ។

**៤.ពេលវេលាសម្រាប់ធ្វើការ**

សមាជិកត្រូវបំពេញការងារតាមវេលាកាល និងយោងតាមភាពចាំបាច់ ដែលកំណត់ផ្អែកតាមការកោះអញ្ជើញរបស់ប្រធានក្រុមហ៊ុន ។

**៥.ការប្រឡងជ្រើសរើស**

៥.១ កាលបរិច្ឆេទប្រឡង នឹងជូនដំណឹងនៅក្រោយសេចក្ដីសម្រេចរបស់ប្រធានក្រុមហ៊ុន ។

៥.២ ការប្រឡងធ្វើឡើងនៅទីស្នាក់ការ ក្រុមហ៊ុនមេធាវីតម្រាច្បាប់ ផ្ទះលេខ១៨១ ផ្លូវលេខ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥.៣ ការប្រឡងធ្វើឡើង តាមរយៈការសម្ភាសន៍ដោយផ្ទាល់មាត់នូវចំណេះជំនាញ និងលក្ខណៈសម្បត្តិដែលជាលក្ខខណ្ឌនៃការជ្រើសរើស ។

**៦.កាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យ**

កាលបរិច្ឆេទទទួលពាក្យ ចាប់ផ្ដើមពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ ។ បេក្ខជន ឬ បេក្ខនារី ដែលមានបំណង និង ចំណាប់អារម្មណ៍ចង់ចូលរួម សូមធ្វើការទាញយកពាក្យសុំចូលរួមប្រឡងជ្រើសរើស តាមរយៈតំណភ្ជាប់ឯកសារនៅក្នុងគេហទំព័រ របស់ក្រុមហ៊ុនមេធាវីតម្រាច្បាប់ www.legalcodelawfirm.com/kh/document/106 ដើម្បីបំពេញបែបបទ និងអញ្ជើញមកដាក់ដោយផ្ទាល់នៅទីស្នាក់ការ ក្រុមហ៊ុនមេធាវីតម្រាច្បាប់ នៅរៀងរាល់ម៉ោងធ្វើការ ឬអាចដាក់ពាក្យសុំតាមរយៈតេឡេក្រាមដែលមានគណនីលេខទូរស័ព្ទ ០៩២ ២៩ ៩៩ ៣៤ ឱ្យបានមុនកាលបរិច្ឆេទកំណត់ ។ ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ ០៦៩ ៥៧៧ ៧៧៩ / ០៩៩ ៤៧៤ ៤៩៩ ។

ថ្ងៃសុក្រ ១៣ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

**ក្រុមហ៊ុនមេធាវី តម្រាច្បាប់**

LEGAL CODE LAW FIRM



ផ្ទះលេខ ១៨១ ផ្លូវ ១៥០ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Address: #181, St.150, Sangkat Tuek L'ak Ti Pir, Khan Toul Kork, Phnom Penh.
Tel: (+855) 86 262 630 / 92 299 934
Email:info@legalcodecambodia.com